**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ...១០៧...........បទ.ស.ស.រ...........

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៤

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលការបែងចែកភារកិច្ច
# របស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០១៣/១០៩៣ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ ស្តីពីការតែងតាំងឯកឧត្តម សេក សុជាតិ ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២១៤/២០១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការតែងតាំងលោកជំទាវ ម៉ី គឿង និងឯកឧត្តម ជុន វ៉ាត ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង

# សម្រេច

**ប្រការ ១** .-

កែសម្រួលការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សំដៅធានាការដឹកនាំកិច្ចការទូទៅរបស់ក្រសួង និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២** .-

**រដ្ឋមន្ត្រី ៖** រដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំការងាររួមរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ចាត់ចែង និងបញ្ជារាល់សកម្មភាពលើគ្រប់វិស័យពាក់ព័ន្ធ និងដឹកនាំផ្ទាល់លើការងាររដ្ឋបាល, បុគ្គលិក និងបណ្តុះបណ្តាល, ផែនការ , ហិរញ្ញវត្ថុ , អធិការកិច្ច និងសវនកម្មផ្ទៃក្នុង ។

**រដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **សារ៉ាត់ ខាន់** : ទទួលបន្ទុកជារដ្ឋមន្ត្រីស្តីទីពេលរដ្ឋមន្ត្រីអវត្តមាន តាមរយៈលិខិតប្រគល់សិទ្ធិ និងជួយរដ្ឋមន្ត្រីអំពីកិច្ចការនីតិកម្ម, ការងារអង្គភាពបញ្ញត្តិករទូរគមនាគមន៍កម្ពុជា (T.R.C)និងការងារហិរញ្ញវត្ថុ ព្រមទាំងពិនិត្យនិងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តមណ្ឌលគីរី និងការងារប្រៃសណីយ៍ និងទូរគមនាគមន៍រាជធានីភ្នំពេញ ។

២- ឯកឧត្តម **ខាយ ឃុនហេង** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការងារផែនការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, កម្មវិធីវិនិយោគសាធារណៈ (P.I.P) និងការងារសវនកម្មផ្ទៃក្នុង ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតាកែវ , កំពត និងកែប ។

៣- ឯកឧត្តម **ឯក វណ្ណឌី** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីគោលនយោបាយអភិវឌ្ឍវិស័យប្រៃសណីយ៍, ទំនាក់ទំនងអន្តរជាតិលើវិស័យប្រៃសណីយ៍ និងការងារអង្គភាពប្រៃសណីយ៍កម្ពុជា(C.P) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប, និងកំពង់ធំ ។

៤- លោកជំទាវ **រស់ សុវគ្នា** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍, ការងារមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ (D.M.C) និងកិច្ចការយេនឌ័រ (Gender) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបន្ទាយមានជ័យ និងបាត់ដំបង ។

៥- ឯកឧត្តម **ភាន ច័ន្ទមេត្តា** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការងារសហប្រតិបត្តិការអន្តរជាតិ , វិស័យ ICT និងការងារអង្គភាពទូរគមនាគមន៍កម្ពុជា(T.C) ព្រមទាំងពិនិត្យនិងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ និងកោះកុង ។

៦- លោកជំទាវ **ប្រាក់ ច័ន្ទណាយ** : ទទួលបន្ទុកជួយរដ្ឋមន្ត្រីអំពីការត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ និងកិច្ចការយេនឌ័រ (Gender) ព្រមទាំងពិនិត្យ និងតាមដានការអនុវត្តការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្វាយរៀង និងព្រៃវែង ។

**អនុរដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **ឌី ចន** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការងារសម្របសម្រួលកិច្ចការនីតិកម្ម, ការងាររបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា(T.R.C)និងទំនាក់ទំនងអន្តរជាតិលើវិស័យប្រៃសណីយ៍, ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តកំពង់ឆ្នាំង ។

២- ឯកឧត្តម **ភុយ ពុំ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការងាររដ្ឋបាល, បុគ្គលិក និងបណ្តុះបណ្តាល ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកំពង់ស្ពឺ, ព្រះសីហនុ និងកោះកុង ។

៣- ឯកឧត្តម **មាស ម៉ូ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារសហប្រតិបត្តិការអន្តរជាតិ និងការងាររបស់អង្គភាពទូរគមនាគមន៍កម្ពុជា(T.C) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ ។

៤- ឯកឧត្តម **ចាយ ណារ៉ុធ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារគោលនយោបាយអភិវឌ្ឍវិស័យប្រៃសណីយ៍, អធិការកិច្ច និងសវនកម្មផ្ទៃក្នុង ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម , ត្បូងឃ្មុំ និងក្រចេះ ។

៥- លោកជំទាវ **ទ្រឹង មុន្នីរង្សី** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលកិច្ចការគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍, ភាពប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍ និងកិច្ចការយេនឌ័រ (Gender) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល និងតាកែវ ។

៦- ឯកឧត្តម **អេ សុតា** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងាររបស់មជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ(D.M.C)និងការងារបូកសរុប ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបាត់ដំបង និងប៉ៃលិន ។

៧- ឯកឧត្តម **ខូវ មករា** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារផែនការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, កម្មវិធីវិនិយោគសាធារណៈ(P.I.P), ការងារសហប្រតិបត្តិការអន្តរជាតិខាងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(I.C.T) ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះវិហារ ។

៨- ឯកឧត្តម **សេក សុជាតិ** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្ទឹងត្រែង និងរតនគីរី ។

៩- លោកជំទាវ **ម៉ី តឿង** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ ។

១០- ឯកឧត្តម **ជុន វ៉ាត** : ជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការអំពីការសម្របសម្រួលការងារអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងសម្របសម្រួលការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពត និងកែប ។

**ប្រការ ៣** .-

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ អាចទទួលបន្ទុកការងារបន្ថែមមួយចំនួនទៀតតាមការចាំបាច់ដែលរដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៤** .-

និរាករណ៍សេចក្តីសម្រេចលេខ១៣២បទ.សសរ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ និងសេចក្តីសម្រេចលេខ១៤៩បទ.សសរ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ និងសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ។

**ប្រការ ៥** .-

រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦** .-

សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
« ដើម្បីជូនជ្រាប »
-ដូចប្រការ ៥ « ដើម្បីអនុវត្ត »
-ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

ប្រាក់_សុខុន